ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ខេត្ត ពោធិ៍សាត់

ស្រុកក្រគរ

ឃុំស្នាអន្សា

លេខ:០០១/១៨

# ដីកា
# ស្តីពី
# ការបង្ការនិងទប់ស្កាត់គ្រោះថ្នាក់ដែលបណ្តាលមកពីការប្រើប្រាស់គ្រឿងស្រវឹង

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ/សង្កាត់
- បានឃើញអនុក្រិត្យលេខ ២២ អនក្រ.បក ចុះថ្ងៃទី២៥ ខែមិនា ឆ្នាំ២០០២ ស្តីពីការធ្វើវិមជ្ឈការអំណាច តួនាទី និង ភារកិច្ច ទៅអោយក្រុមប្រឹក្សាឃុំ/សង្កាត់
- បានឃើញប្រកាសលេខ: ២០៤២ ប្រ.ក ចុះថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០១៧ ស្តីពីការទទួលស្គាល់សមាសភាព សមាជិក ក្រុមប្រឹក្សាឃុំ មេឃុំ ជំទប់ទី១ និងជំទប់ទី២ នៃឃុំស្នាអន្សា ស្រុកក្រគរ ខេត្តពោធិ៍សាត់ ។
- យោងសៀវភៅឯកសារបច្ចេកទេសស្តីពី ការបង្កា និងទប់ស្កាត់គ្រឿងស្រវឹងសម្រាប់រដ្ឋបាលឃុំ/សង្កាត់ របស់ក្រសួងមហាផ្ទៃលេខ ០២ស.ស.រ/គ.ជ.អ.ប ចុះថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០១៧
- យោងកិច្ចប្រជុំកាលពីថ្ងៃព្រហស្បត៍ ០៤ រោច ខែស្រាពណ៍ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២ ត្រូវនិងថ្ងៃទី ៣០ ខែសីហា ឆ្នាំ២០១៨ របស់ក្រុមប្រឹក្សាឃុំ ស្តីពីការបង្ការនិងកាត់បន្ថយផលប៉ះពាល់នៃគ្រឿងស្រវឹងក្នុងឃុំស្នាអន្សា ។
- យោងតាមតម្រូវការចំបាច់របស់រដ្ឋបាលឃុំ

ដោយយល់ឃើញថា បញ្ហាដែលបង្កឡើងដោយអ្នកប្រើសប្រាស់គ្រឿងស្រវឹងបានធ្វើអោយមានអំពើហឹង្សា ភាពឥត សណ្តាប់ធ្នាប់ អសន្តិសុខភាពក្រីក្រនិងប៉ះពាល់ដល់សុខភាពជារួមរបស់ប្រជាពលរដ្ឋនៅក្នុងឃុំស្នាអន្សា ដូច្នេះទើប ក្រុមប្រឹក្សាឃុំស្នាអន្សា ៖

## <u>សម្រេច</u>

-ប្រការ១ ៖ ដីកានេះមានគោលបំណងការពារសិទ្ធស្ត្រី សិទ្ធកុមារ និងបង្ការអំពើហិង្សា ព្រមទាំងលើកកំពស់សុខមាលភាព និងប្រាក់ចំណូលប្រជាពលរដ្ឋ ក៏ដូចជារក្សាសន្តិសុខ សណ្តាប់ធ្នាប់ និងសុវត្ថិភាពក្នុងឃុំស្នាអន្សា ទាំងមូល ។

-ប្រការ២ ៖ ដីកាមានវិសាលភាពអនុវត្តទៅលើ អ្នកប្រើប្រាស់គ្រឿងស្រវឹងដែលបង្កបញ្ហា ឬបង្កការរំខាន បង្កហិង្សា នានា ព្រមទាំងការលក់ ផលិតផលគ្រឿងស្រវឹងទៅអោយជនទាំងឡាយណា ឬទីកន្លែងមួយចំនួនក្នុងឃុំ ស្នាអន្សា ដែលមានចែង ក្នុងប្រការនេះ ។

-ប្រការ៣ ៖ មេភូមិគ្រប់ភូមិ ក្រុមប្រឹក្សាឃុំ ព្រះចៅអធិការវត្ត ព្រះសង្ឃ សហគមន៍ នាយកសាលា មណ្ឌលសុខភាព និង សមាជិកគ្រួសារ ត្រូវបង្កើនការផ្សព្វផ្សាយពីផល ប៉ះពាល់នៃគ្រឿងស្រវឹងទៅដល់ប្រជាពលរដ្ឋក្នុងឃុំឲបាន

ទូលំ ទូលាយ ។ក្នុងត្រូវមានការណែនាំអ្នកប្រើប្រាស់គ្រឿងស្រវឹងជាប្រចាំ ឲ្យពួកគាត់កាត់បន្ថយ និងធ្វើការងារ ក៏ដូចជាលេងកីឡាផ្សេងៗឲ្យបានច្រើន ។ករណីអ្នកស្រវឹងបង្កបញ្ហាត្រូវរាយការណ៍ ជូនសមត្ថកិច្ចដើម្បីមានវិធានការតាមផ្លូវច្បាប់ ។

-ប្រការ៤ ៖ ហាមក្មេងអាយុក្រោម ១៨ ឆ្នាំ ផឹកគ្រឿងស្រវឹង និងមិនត្រូវលក់គ្រឿងស្រវឹងអោយក្មេងអាយុក្រោម ១៨ ឆ្នាំនៅឡើយ។ជនគ្រប់រូបមិនត្រូវប្រើក្មេងអាយុក្រោម ១៨ ឆ្នាំទៅទិញគ្រឿងស្រវឹងនោះទេ ។

-ប្រការ៥ ៖ ហាមលក់ និងផឹកគ្រឿងស្រវឹងគ្រប់ប្រភេទនៅក្នុងវត្តអារាម គ្រឹស្ថានសាសនា សាលារៀន សាលាឃុំ ប៉ុស្តិ៍រដ្ឋបាលឃុំ មណ្ឌលសុខភាព ស្នាក់ការភូមិ និងអគាសាធារណៈនានា ។

-ប្រការ៦ ៖ ហាមលើកផ្ទាំងផ្សាយពាណិជ្ជកម្មគ្រឿងស្រវឹងគ្រប់ប្រភេទ នៅផ្នែកខាងក្នុង និងក្រៅបរិវេនវត្តអារាម គ្រិះស្ថានសាសនា សាលារៀន សាលាឃុំ ប៉ុស្តិរដ្ឋបាលឃុំ សាលារៀន សាលាឃុំ ប៉ុស្តិ៍រដ្ឋបាលឃុំ មណ្ឌលសុខភាព ស្នាក់ការភូមិ និងអគាសាធារណៈនានា ។

-ប្រការ៧ ៖ ហាមជនគ្រប់រូបប្រើប្រាស់គ្រឿងស្រវឹង ហើយឡូឡា ឬប្រើម៉ូតូឡានដែលមានសំលេង រំខាន(កែច្នៃខុសពីបច្ចេកទេសដើម) ឬឧបករណ៍បំពងសំលេងផ្សេងៗដែលបង្កការរំខានដល់អ្នកដ៏ទៃចាប់ម៉ោង១០ យប់ដល់ម៉ោង៦ ព្រឹក។

-ប្រការ៨ ៖ ជនណាដែលល្មើសនិង ប្រការ ៤,៥,៦ និងប្រការ៧ ដូចដែលបានចែងខាងលើនេះ ត្រូវធ្វើការណែនាំលើកទី១ ដោយផ្ទាល់មាត់ លើកទី២ ជាលាយល័កអក្សរ និងលើកទី៣ ។ក្នុងករណី៣លើកនៅមិនរាងចាល អជ្ញាធរឃុំ ឬនគបាលប៉ុស្តិត្រូវពិន័យជាសាច់ប្រាក់ចាប់ពី ២០.០០០រៀល(ពីម៉ឺនរៀល)ដល់១០០.០០០រៀល(ដប់ម៉ឺនរៀលគត់)

-ប្រការ៩ ៖ ថវិកាដែលទទួលបានពីការផាកពិន័យត្រូវដាក់បញ្ចូលជាថវិកាមូលិធិសម្រាប់ជួយកុមារកំព្រា និងចាស់ជរាឥតទីពឹង ដែលមានទីលំនៅក្នុងឃុំស្នាអន្សា ។

-ប្រការ១០ ៖ ឃុំត្រូវបង្កើតគណកម្មការ និងជនបង្គោលតាមភូមិស្ម័គ្រចិត្តសម្រាប់ជួយផ្សព្វផ្សាយ ឲ្យមានប្រសិទ្ធភាពនៃការអនុវត្តន៍ ដីការឃុំ បន្ទាប់ពីបានអនុម័តអោយប្រើប្រាស់ជាផ្លូវការ ។

-ប្រការ១១ ៖ឃុំនិងត្រូវដាក់បញ្ចូលកម្មវិធីអប់រំផ្សព្វផ្សាយផលប៉ះពាល់ស្តីពីការប្រើប្រាស់គ្រឿងស្រវឹង និងការធ្វើសកម្មភាពផ្សព្វផ្សាយពីដីកាឃុំ ទៅក្នុងផែនការអភិវឌ្ឍន៍របស់ឃុំ សម្រាប់ធ្វើសម្មភាព ផ្សព្វផ្សាយដល់ប្រជាពលរដ្ឋនៅតាមភូមិនីមួយៗនៅក្នុងឃុំ ។

-ប្រការ១២ ៖ អាជ្ញាធមូលដ្ឋាន(មេឃុំ ក្រុមប្រឹក្សាឃុំ មេភូមិ នគរបាលប៉ុស្តិរដ្ឋបាលឃុំ)មណ្ឌលសុខភាព ព្រះសង្ឃ គ្រូបឋម និងសហគន៍ ត្រូវធ្វើការផ្សព្វផ្សាយដីកានេះជូនប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធក្នុងមូលដ្ឋានអោយបានទូលំទូលាយ។

-ប្រការ១៣៖ ដីការមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃអង្គារ៍ ០៧ កើត ខែអស្សុជ ឆ្នាំច សំរិទ្ធិស័ក ព.ស ២៥៦២

ធ្វើនៅស្នាអន្សា ថ្ងៃទី១៦ ខែតុលា ឆ្នាំ ២០១៨

មេឃុំស្នាអន្សា

សោភ_គៅ